ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
******

## ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន អះអាងថា
## កម្ពុជាបន្តប្រកាន់ខ្ជាប់របបប្រជាធិបតេយ្យសេរីពហុបក្ស

ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអះអាងយ៉ាងច្បាស់ថា កម្ពុជាបាននិងកំពុងខិតខំធ្វើអ្វីៗទាំងអស់ដើម្បីរក្សាសន្តិភាព និងស្ថិរភាព បម្រើឲ្យផលប្រយោជន៍ប្រទេសជាតិ ហើយកម្ពុជានឹងបន្តប្រកាន់ខ្ជាប់របបប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញរបស់ប្រទេស។ ការអះអាងបែបនេះ ត្រូវបានធ្វើឡើងក្នុងឱកាស ឯកឧត្តមទេសរដ្ឋមន្ត្រី ទទួលជួបលោក Gunnar Wiegand មន្ត្រីជាន់ខ្ពស់របស់សហភាពអឺរ៉ុប និងជានាយកគ្រប់គ្រងសេវាកិច្ចការបរទេសរបស់អឺរ៉ុប (European External Action Service Managing Director) និងឯកឧត្តម George Edgar ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុបប្រចាំកម្ពុជា នៅព្រឹកថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង០៩:៣០ នៅទីស្ដីការក្រសួង។

នៅក្នុងការពិភាក្សាផ្លាស់ប្តូរយោបល់ដែលបានប្រព្រឹត្តទៅក្នុងបរិយាកាសត្រង់ទៅត្រង់មក ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** និងលោក Gunnar Wiegand បានស្របទស្សនៈគ្នាក្នុងការវាយតម្លៃខ្ពស់ប្រកបដោយការពេញចិត្ត ចំពោះការវិវត្តដ៏ល្អប្រសើរក្នុងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការរវាងសហភាពអឺរ៉ុប និងព្រះរាជាណាចក្រកម្ពុជា ពិសេសគឺការរីកចម្រើនលើការផ្លាស់ប្តូរពាណិជ្ជកម្ម ការផ្តល់ជំនួយអភិវឌ្ឍន៍ និងជំនួយផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុសម្រាប់ការបោះឆ្នោតនៅកម្ពុជា ហើយនិងការកើនឡើងនូវទំនាក់ទំនងទេសចររវាងសហភាពអឺរ៉ុប-កម្ពុជា។

លោក Gunnar Wiegand បានគូសបញ្ជាក់ពីក្តីសង្ឃឹមរបស់សហភាពអឺរ៉ុបក្នុងការបន្តនូវទំនាក់ទំនងដ៏ល្អនេះ ជាមួយនឹងកម្ពុជា ក្នុងអនាគតទៅមុខទៀត។ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានសម្តែងនូវអំណរគុណ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ចំពោះជំនួយអភិវឌ្ឍន៍របស់សហភាពអឺរ៉ុប ហើយបានអះអាងអំពីបំណងប្រាថ្នាដូចគ្នានេះដែររបស់កម្ពុជា ក្នុងការបន្តនូវកិច្ចសហប្រតិបត្តិការដ៏ល្អនេះ។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានរំលឹកឡើងវិញពីជំនួបរបស់ឯកឧត្តម ជាមួយគណៈប្រតិភូរបស់សភាអឺរ៉ុប ដឹកនាំដោយឯកឧត្តម Werner Langen ប្រធានគណៈកម្មាធិការកិច្ចការសេដ្ឋកិច្ច និងរូបិយវត្ថុរបស់សភាអឺរ៉ុប កាលពីថ្ងៃទី៣០ ខែតុលា កន្លងមក ដែលក្នុងនោះ ឯកឧត្តម បានផ្តល់ការឆ្លើយបំភ្លឺជាច្រើនចំពោះការសាកសួររបស់គណៈប្រតិភូ អំពីសភាពការណ៍នៅកម្ពុជា ហើយគណៈប្រតិភូក៏បានបង្ហាញពីការយល់ដឹងរបស់ខ្លួន។

ឆ្លើយតបទៅនឹងការលើកឡើងរបស់លោក Gunnar Wiegand អំពីការព្រួយបារម្ភចំពោះសភាពការណ៍បច្ចុប្បន្ននៅកម្ពុជា **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានធ្វើការបំភ្លឺ បកស្រាយដោយលម្អិតលើករណី៖

បញ្ហាសង្គមស៊ីវិល ៖ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ ថា កម្ពុជាជាប្រទេសមួយដែលត្រូវបានគេមើលឃើញថាមានសកម្មភាពខ្លាំងលើផ្នែកសង្គមស៊ីវិល ជាមួយវត្តមានរបស់អង្គការក្រៅរដ្ឋាភិបាលជាង៥០០០។ ករណីការបញ្ឈប់សកម្មភាពអង្គការ NDI គឺបង្ករឡើងដោយអង្គការនេះខ្លួនឯង ដែលមិនបានគោរពទៅតាមច្បាប់ស្តីពីអង្គការNGOs របស់កម្ពុជា ដែលពីមុននិងក្រោយពេលនៃការចូលជាធរមានរបស់ច្បាប់នេះ អង្គការNDI ពុំបានចុះអនុស្សរណៈជាមួយក្រសួងការបរទេសឡើយ ហើយប្រការនេះ ធ្វើឲ្យក្រសួងការបរទេសពុំមានជម្រើសណាក្រៅពីបង្ខំចិត្តបញ្ឈប់សកម្មភាពរបស់អង្គការនេះ នៅកម្ពុជាឡើយ។

ចំពោះករណីសេរីភាពខាងសារព័ត៌មាន **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់យ៉ាងច្បាស់ថា កម្ពុជា ត្រូវបានអង្គការអ្នករាយការណ៍គ្មានព្រំដែនទទួលស្គាល់ថា ស្ថិតក្នុងលំដាប់ទី១ ក្នុងចំណោមប្រទេសអាស៊ានទាំង១០។ ករណីកាសែត The Cambodia Daily គឺជាករណីពាក់ព័ន្ធនឹងច្បាប់ស្តីពីពន្ធដារ ដែលក្នុងពេលដែលកាសែតភាសាបរទេសឯករាជ្យចំនួនពីរផ្សេងទៀត បានគោរពនិងបានបង់ពន្ធជូនរដ្ឋ កាសែត The Cambodia Daily ពុំបានបង់ពន្ធជូនរដ្ឋឡើយ ហើយនៅពេលដែលកម្ពុជាតំរូវឲ្យគោរពទៅតាមច្បាប់ស្តីពីពន្ធដារ កាសែត The Cambodia Daily បានសម្រេចចិត្តបិទទ្វារដោយខ្លួនឯង។

ចំពោះករណីការប្តឹងរំលាយគណបក្សសង្គ្រោះជាតិ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា អាជ្ញាធរមានសមត្ថកិច្ចកម្ពុជាបានដាក់ពាក្យបណ្តឹងភ្ជាប់ជាមួយភស្តុតាងទាំងអស់ ទៅតុលាការកំពូល ហើយអ្វីៗអាស្រ័យលើការវិនិច្ឆ័យរបស់តុលាការកំពូល។

បន្ទាប់ពីការបកស្រាយបំភ្លឺនេះ **ឯកឧត្តមទេសរដ្ឋមន្ត្រី** បានអះអាងបញ្ជាក់យ៉ាងច្បាស់ថា ករណីទាំងបីនេះ គឺជាការពង្រឹងនីតិរដ្ឋនៅកម្ពុជាដោយសុទ្ធសាធ ពុំមែនដូចជាការបកស្រាយរបស់មជ្ឈដ្ឋានមួយចំនួនដែលថាវាជាបញ្ហាដែលកើតឡើងដោយហេតុផលនយោបាយនោះឡើយ។ ក្នុងករណីមានការសម្រេចរបស់តុលាការកំពូលរំលាយគណបក្សសង្គ្រោះជាតិ ក៏កម្ពុជាពុំវិលត្រលប់ទៅរករបបឯកបក្សឡើយ គឺកម្ពុជានៅតែបន្តប្រកាន់ខ្ជាប់របបប្រជាធិបតេយ្យសេរីពហុបក្ស។

ចំពោះការបោះឆ្នោត **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានជំរាបអំពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការរៀបចំការបោះឆ្នោតជាតិក្នុងឆ្នាំ២០១៨ខាងមុខនេះ ដោយលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ និងអាចទទួលយកបាន ដូចដែលកម្ពុជាធ្លាប់បានធ្វើកន្លងមកក្នុងការបោះឆ្នោតឃុំ-សង្កាត់ ហើយក្នុងការបោះឆ្នោតនោះ ក៏នឹងមានការចូលរួមប្រកួតប្រជែងពីគណបក្សជាច្រើនផងដែរ។

ភ្នំពេញ, ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០១៧